# លំហាត់ត្រីកោណមាត្រ

Training For Mathematical Olympiad

## ភាគ១




រៀបរៀងដោយ ជា ពិសិដ្ឋ

# មាតិកា

ជំពូក ១

មេរៀន និង ទ្រឹស្តី……………………………………………………………………….. 1

ជំពូក ២

ប្រធានលំហាត់ ………………………………………………………………………. 12

ជំពូក ៣

ដំណោះស្រាយ……………………………………………………………………….. 33

# ជំពូក 1

# មេរៀន និង គ្រឹស្តី

# អនុគមន៍ត្រីកោណមាត្រ

## 1. សមភាពត្រីកោណមាត្រ

$$\sin^2 a + \cos^2 a = 1$$

$$1 + \tan^2 a = \frac{1}{\cos^2 a} = \sec^2 a$$

$$1 + \cot^2 a = \frac{1}{\sin^2 a} = \csc^2 a$$

## 2. រូបមន្តផលបូក និង ផលដកមុំ

$$\sin(a \pm b) = \sin a \cos b \pm \sin b \cos a$$

$$\cos(a \pm b) = \cos a \cos b \mp \sin a \sin b$$

$$\tan(a \pm b) = \frac{\tan a \pm \tan b}{1 \mp \tan a \tan b}$$

$$\cot(a \pm b) = \frac{\cot a \cot b \mp 1}{\cot a \pm \cot b}$$

## 3. រូបមន្តមុំឌុប

$$\sin 2a = 2\sin a \cos a = \frac{2\tan a}{1 + \tan^2 a}$$

$$\cos 2a = 2\cos^2 a - 1 = 1 - 2\sin^2 a = \frac{1 - \tan^2 a}{1 + \tan^2 a}$$

$$\tan 2a = \frac{2\tan a}{1 - \tan^2 a}$$

$$\cot 2a = \frac{\cot^2 a - 1}{2\cot a}$$

## 4. រូបមន្តមុំទ្រីប ( មុំ $3a$ )

$$\sin 3a = 3\sin a - 4\sin^3 a$$

$$\cos 3a = 4\cos^3 a - 3\cos a$$

$$\tan 3a = \frac{3\tan a - \tan^3 a}{1 - 3\tan^2 a}$$

5. រូបមន្តកន្លះមុំ

$$\sin^2 \frac{a}{2} = \frac{1-\cos a}{2}$$

$$\cos^2 \frac{a}{2} = \frac{1+\cos a}{2}$$

$$\tan \frac{a}{2} = \frac{1-\cos a}{\sin a} = \frac{\sin a}{1+\cos a}$$

$$\cot \frac{a}{2} = \frac{1+\cos a}{\sin a} = \frac{\sin a}{1-\cos a}$$

6. បំលែងពីផលបូកទៅផលគុណ

$$\sin a + \sin b = 2\sin\left(\frac{a+b}{2}\right)\cos\left(\frac{a-b}{2}\right)$$

$$\cos a + \cos b = 2\cos\left(\frac{a+b}{2}\right)\cos\left(\frac{a-b}{2}\right)$$

$$\tan a + \tan b = \frac{\sin(a+b)}{\cos a \cos b}$$

7. បំលែងពីផលដកទៅផលគុណ

$$\sin a - \sin b = 2\sin\left(\frac{a-b}{2}\right)\cos\left(\frac{a+b}{2}\right)$$

$$\cos a - \cos b = -2\sin\left(\frac{a-b}{2}\right)\sin\left(\frac{a+b}{2}\right)$$

$$\tan a - \tan b = \frac{\sin(a-b)}{\cos a \cos b}$$

8. បំលែងពីផលគុណទៅផលបូក

$$2\sin a \cos b = \sin(a+b) + \sin(a-b)$$

$$2\cos a \cos b = \cos(a-b) + \cos(a+b)$$

$$2\sin a \sin b = \cos(a-b) - \cos(a+b)$$

9. រូបមន្តពហុធា

$$\sin na = C_n^1 \cos^{n-1} a \sin a - C_n^3 \cos^{n-3} a \sin^3 a + C_n^5 \cos^{n-5} a \sin^5 a - \dots$$

$$\cos na = C_n^0 \cos^n a - C_n^2 \cos^{n-2} a \sin^2 a + C_n^4 \cos^{n-4} a \sin^4 a - \dots$$

# ទ្រឹស្តីបទ និង រូបមន្ត( ធរណីមាត្រក្នុងប្លង់ )

1. **ទ្រឹស្តីបទស៊ីនុស**

បើ $R$ ជាប្រវែងកាំនៃរង្វង់ចារឹកក្រៅត្រីកោណ $ABC$ គេបាន

$$\frac{a}{\sin A}=\frac{b}{\sin B}=\frac{c}{\sin C}=2R$$ ។

2. **ទ្រឹស្តីបទកូស៊ីនុស**

បើ $ABC$ មានប្រវែងជ្រុង $AB=c$ , $BC=a$ , $AB=b$ គេបាន

$$a^2=b^2+c^2-2bc\cos A$$

$$b^2=c^2+a^2-2ca\cos B$$

$$c^2=a^2+b^2-2ab\cos C$$ ។

3. **ទ្រឹស្តីបទ** Stewart

ចំពោះ $ABC$ ជាត្រីកោណមួយ និង $D$ នៅលើជ្រុង $BC$ គេបាន

$d^2a+man=c^2n+b^2m$ ក្នុងនោះ $m=BD$ , $n=DC$ និង

$d=AD$ ។

រូបមន្តនេះ អាចបង្ហាញប្រវែងនៃកម្ពស់ និង កន្លះបន្ទាត់មុំនៃត្រីកោណ $ABC$ ជាអនុគមន៍នៃជ្រុងរបស់វា ។

4. **ទ្រឹស្តីបទ** Ptolemy

បើ $ABCD$ ជាចតុកោណចារឹកក្នុងរង្វង់ គេបានសមភាព

$AB\cdot CD+AD\cdot BC=AC\cdot BD$ ។

5. **ទ្រឹស្តីបទ** Céva

យក $D$ , $E$ , $F$ ជាបីចំណុចនៅលើជ្រុង $BC$ , $CA$ និង $AB$ រៀងគ្នានៃ

ត្រីកោណ $ABC$ គេបាន លក្ខខណ្ឌទាំងបីខាងក្រោមសមមូលគ្នា

(i). $AD$, $BE$, $CF$ ប្រសព្វគ្នាត្រង់មួយចំណុច

(ii). $\frac{\sin\angle ABE}{\sin\angle DAB}\cdot\frac{\sin\angle BCF}{\sin\angle EBC}\cdot\frac{\sin\angle CAD}{\sin\angle FCA}=1$

(iii). $\frac{AF}{FB}\cdot\frac{BD}{DC}\cdot\frac{CE}{EA}=1$ ។

6. **ទ្រឹស្តីបទ** Menelaus

យក $F$, $G$, $H$ ជាចំណុចនៅលើជ្រុង $BC$, $CA$ និង $AB$ នៃត្រីកោណ $ABC$ រៀងគ្នា ។ គេបាន $F$, $G$, $H$ ស្ថិតនៅលើបន្ទាត់តែមួយ លុះត្រាតែ $\frac{AH}{HB}\cdot\frac{BF}{FC}\cdot\frac{CG}{GA}=1$ ។

7. **រូបមន្ត** Euler

យក $O$, $I$ ជាផ្ចិតរង្វង់ចារឹកក្រៅ និង ក្នុងរៀងគ្នានៃត្រីកោណ $ABC$ ។ គេបាន $OI^2=R^2-2rR$ ដែល $R$ ជាកាំរង្វង់ចារឹកក្រៅ និង $r$ ជាកាំរង្វង់ចារឹកក្នុង ។

8. **រូបមន្ត** Brahmagupta

បើ $ABCD$ ជាចតុកោណចារឹកក្នុងរង្វង់ និង មាន $AB=a$, $BC=b$, $CA=c$, $DA=d$ និង $s=\frac{a+b+c+d}{2}$ (កន្លះបរិមាត្រ)

គេបាន $[ABCD]=\sqrt{s(s-a)(s-b)(s-c)(s-d)}$ ។

9. **រូបមន្ត ហេរុង** (Heron)

បើ $ABC$ ជាត្រីកោណដែលមានប្រវែងជ្រុង $a$, $b$, $c$ គេបាន

$[ABC]=\sqrt{s(s-a)(s-b)(s-c)}$ ដែល $s=\frac{a+b+c}{2}$

ជាកន្លះបរិមាត្រនៃត្រីកោណ $ABC$ ។

10. រូបមន្តមេដ្យាន

បើ $AM$ ជាមេដ្យាននៃត្រីកោណ $ABC$ គេបាន

$$AM^2 = \frac{2AB^2 + 2AC^2 - BC^2}{4}$$ ។

# វិសមភាព

## 1. វិសមភាពនៃមធ្យម

បើ $a_1$, $a_2$, … , $a_n$ ជា $n$ ចំនួនពិតវិជ្ជមាន គេកំណត់យក

$AM = \frac{a_1 + a_2 + ... + a_n}{n}$ ហៅថា មធ្យមព្វន្ត (Arithmetic Mean)

$GM = \sqrt[n]{a_1 a_2 ... a_n}$ ហៅថា មធ្យមធរណីមាត្រ (Geometric Mean)

$QM = \sqrt{\frac{a_1^2 + a_2^2 + ... + a_n^2}{n}}$ ហៅថា មធ្យមរឺសការេ (Quadratic Mean)

និង $HM = \frac{n}{\frac{1}{a_1} + \frac{1}{a_2} + ... + \frac{1}{a_n}}$ ហៅថា មធ្យមអាម៉ូនិច (Harmonic Mean) ។

យើងបាន វិសមភាព $QM \geq AM \geq GM \geq HM$

សមភាពកើតឡើងពេល $a_1 = a_2 = ... = a_n$ ។

**សម្គាល់**

វិសមភាព $AM \geq GM$ មានអ្នកខ្លះហៅថា វិសមភាព Cauchy ។

## 2. វិសមភាព Cauchy-Schwarz

ចំពោះ $2n$ ចំនួនពិត $a_1$, $a_2$, … , $a_n$ និង $b_1$, $b_2$, … , $b_n$ គេបាន

$$(a_1 b_1 + a_2 b_2 + ... + a_n b_n)^2 \leq (a_1^2 + a_2^2 + ... + a_n^2)(b_1^2 + b_2^2 + ... + b_n^2)$$

សមភាពពេល $\vec{u} = (a_1, a_2, ..., a_n)$, $\vec{v} = (b_1, b_2, ..., b_n)$ កូលីនេអ៊ែរគ្នា។

## 3. មធ្យមស្វ័យគុណ

យក $a_1$, $a_2$, … , $a_n$ ជា $n$ ចំនួនពិតវិជ្ជមានបំពេញលក្ខខណ្ឌ $\sum_{i=1}^{n} a_i = 1$ ។

ចំពោះ $x_1$, $x_2$, … , $x_n$ ជាចំនួនពិតវិជ្ជមាន គេកំណត់យក

$M_{-\infty} = \min\{x_1, x_2, ..., x_k\}$

$M_{\infty} = \max\{x_1, x_2, ..., x_k\}$

$M_0 = x_1^{a_1} x_2^{a_2} \dots x_n^{a_n}$

$M_t = \left(a_1 x_1^t + a_2 x_2^t + \dots + a_k x_k^t\right)^{\frac{1}{t}}$ ចំពោះ $t$ ជាចំនួនពិតមិនសូន្យ ។

គេបាន $M_{-\infty} \le M_s \le M_t \le M_\infty$ ចំពោះ $s \le t$ ។

## 4. វិសមភាពតម្រៀប (Rearrangement)

បើ $a_1 \le a_2 \le \dots \le a_n$ និង $b_1 \le b_2 \le \dots \le b_n$ ជាចំនួនពិត និង $c_1$ , $c_2$ , … , $c_n$ ជាចម្លាស់នៃ $b_1 \le b_2 \le \dots \le b_n$ គេបាន វិសមភាព

$$a_1 b_n + a_2 b_{n-1} + \dots + a_n b_1 \le a_1 c_1 + a_2 c_2 + \dots + a_n c_n$$
$$\le a_1 b_1 + a_2 b_2 + \dots + a_n b_n$$

សមភាពពេល $a_1 = a_2 = \dots = a_n$ រឺ $b_1 = b_2 = \dots = b_n$ ។

## 5. វិសមភាព Chebyshev

គេមាន $a_1$ , $a_2$ ,…, $a_n$ និង $b_1$ , $b_2$ , … , $b_n$ ជាពីរស្វ៊ីតចំនួនពិតវិជ្ជមាន ។

បើ $a_1 \le a_2 \le \dots \le a_n$ និង $b_1 \le b_2 \le \dots \le b_n$ គេបាន

$$\frac{1}{n}\left(x_1 + x_2 + \dots + x_n\right)\left(y_1 + y_2 + \dots + y_n\right) \le x_1 y_1 + x_2 y_2 + \dots + x_n y_n$$ ។

បើ $a_1 \le a_2 \le \dots \le a_n$ និង $b_1 \ge b_2 \ge \dots \ge b_n$ គេបាន

$$\frac{1}{n}\left(x_1 + x_2 + \dots + x_n\right)\left(y_1 + y_2 + \dots + y_n\right) \ge x_1 y_1 + x_2 y_2 + \dots + x_n y_n$$ ។

## 6. វិសមភាព Schur

ចំពោះគ្រប់ $x$ , $y$ , $z$ ជាចំនួនពិតវិជ្ជមាន យើងបាន វិសមភាព

$$x^r(x-y)(x-z) + y^r(y-z)(y-x) + z^r(z-x)(z-y) \ge 0$$

សមភាពពេល $x = y = z$ រឺ ពីរក្នុងចំណោម $x$ , $y$ , $z$ ស្មើគ្នា ហើយចំនួនមួយទៀតស្មើនឹង $0$ ។

## 7. វិសមភាព Jensen

បើ $f$ ផតលើ $[a,b]$ និង $t_1$ , $t_2$ , … , $t_n \in [0,1]$ ដែល $\sum_{i=1}^{n} t_i = 1$ គេបាន

$$f\left(t_1 x_1 + t_2 x_2 + \dots + t_n x_n\right) \le t_1 f(x_1) + t_2 f(x_2) + \dots + t_n f(x_n)$$

ចំពោះគ្រប់ $x_1$ , $x_2$ , … , $x_n \in [a,b]$ ។

- បើ $t_1 = t_2 = \ldots = t_n = \frac{1}{n}$ យើងបាន

$$f\left(\frac{x_1 + x_2 + \ldots + x_n}{n}\right) \geq \frac{f(x_1) + f(x_2) + \ldots + f(x_n)}{n}$$

**សម្គាល់**

បើ $f$ ប៉ោងលើ $[a,b]$ នោះវិសមភាពប្តូរទិសដៅ ។

# ពហុធា

## 1. ផលបូកស៊ីក្លីក (Cyclic Sum)

បើ $f$ គឺជាអនុគមន៍ $n$ អថេរ គេកំណត់ផលបូកស៊ីគ្លីកនៃអថេរ $(x_1, x_2, ..., x_n)$ ដោយ $\sum_{cyc} f(x_1, x_2, ..., x_n) = f(x_1, x_2, ..., x_n) + f(x_2, x_3, ..., x_n, x_1)$

$+ f(x_n, x_1, ..., x_{n-1})$ ។

## 2. Gauss's Lemma

យក $p(x) = a_n x_n + a_{n-1}x^{n-1} + ... + a_1 x + a_0$ ជាពហុធាដែលមានមេគុណជាចំនួនគត់ ។ រឹសសនិទានទាំងអស់( បើមាន ) នៃពហុធា $p(x)$អាចសរសេរជារាង $\frac{m}{n}$ ដែល $m|a_0$ និង $n|a_n$ ។

## 3. រូបមន្តអាំងទែប៉ូឡាស្យុង Lagrange

យក $x_0$, $x_1$, … , $x_n$ ជាចំនួនពិតផ្សេងគ្នា និង $y_0$, $y_1$, … , $y_n$ ជាចំនួនពិត។ គេបាន មានតែមួយគត់ពហុធា $P(x)$ ដែលមានដឺក្រេធំបំផុត $n$ ផ្ទៀងផ្ទាត់ $P(x_i) = y_i$ ចំពោះ $i = \overline{0, n}$ កំណត់ដោយ

$$P(x) = \sum_{i=0}^{n} \frac{y_i (x - x_0)...(x - x_{i-1})(x - x_{i+1})...(x - x_n)}{(x_i - x_0)...(x_i - x_{i-1})(x_i - x_{i+1})...(x_i - x_n)}$$ ។

## 4. ទ្រឹស្តីបទ Viéte

បើ $x_1$, $x_2$, … , $x_n$ ជារឹសនៃពហុធា $p(x) = a_n x^n + a_{n-1}x^{n-1} + ... + a_1 x + a_0$ ដែល $a_n \neq 0$ និង $a_0$, $a_1$, … , $a_n \in \mathbb{C}$ យើងបាន

$$x_1 + x_2 + ... + x_n = -\frac{a_{n-1}}{a_n}$$

$$x_1 x_2 + ... + x_i x_j + ... + x_{n-1} x_n = \frac{a_{n-2}}{a_n}$$

…………………………………………………………

$$x_1 x_2 \dots x_n = (-1)^n \frac{a_0}{a_n}$$

## 5. រឺសកុំផ្លិច

បើ $z = a + bi$ ចំពោះ $a$, $b$ ជាចំនួនពិត ជារឺសមួយនៃពហុធា $p(x) = a_n x^n + a_{n-1} x^{n-1} + \dots + a_1 x + a_0$ ដែល $a_n \neq 0$ និង $a_0$, $a_1$, … , $a_n \in \mathbb{C}$ នោះ $\bar{z} = a - bi$ ក៏ជារឺសនៃពហុធានេះដែរ ។

## 6. ពហុធា Minimal

គេហៅពហុធា $p(x)$ ថាជា ពហុធា មិនអាចសម្រួលបាន (Irreducible) បើ $p(x)$ មិនអាចសរសេរជាផលគុណនៃពីរពហុធា( មិនថេរ) ដែលមានមេគុណជាចំនួនគត់ ។

យក $\alpha$ ជារឺសមួយនៃពហុធា $q(x)$ ដែលមានមេគុណជាចំនួនគត់ ។ ក្នុងចំណោមពហុធាដែលមានមេគុណជាចំនួនគត់ និង មេគុណនាំមុខស្មើនឹង $1$ ដែលមាន $\alpha$ ជារឺសមួយ មានមួយមានដឺក្រេតូចបំផុត ។ ពហុធានេះ ហៅថា ពហុធា Minimal នៃ $\alpha$ ។

ឧបមាថា $p(x)$ ជាពហុធា Minimal នៃ $\alpha \Rightarrow p(x)$ មិនអាចសម្រួលបាន

បើ $q(x)$ ជាពហុធាមានមេគុណជាចំនួនគត់បំពេញលក្ខខណ្ឌ $q(\alpha) = 0$

គេបាន $p(x)$ ចែកដាច់ $q(x)$ គឺ $q(x) = p(x)h(x)$ ដែល $h(x)$ ជាពហុធាដែលមានមេគុណជាចំនួនគត់ ។

**សម្គាល់**

ពហុធាដែលមានមេគុណជាចំនួនគត់ និង មេគុណនាំមុខស្មើនឹង $1$ ហៅថា ពហុធាម៉ូនិច (Monic Polynomials) ។

# ជំពូក 2

# ប្រជាលំហាត់

## លំហាត់ ១

គេឲ្យ $\sec x - \tan x = 2$ ។ គណនា $\sec x + \tan x$ ។

## លំហាត់ ២

គេឲ្យ $0° < \theta < 45°$ ។ តម្រៀប $t_1 = (\tan\theta)^{\tan\theta}$ , $t_2 = (\tan\theta)^{\cot\theta}$ , $t_3 = (\cot\theta)^{\tan\theta}$ , $t_4 = (\cot\theta)^{\cot\theta}$ តាមលំដាប់ចុះ ។

## លំហាត់ ៣

គណនា

(a) $\sin\dfrac{\pi}{12}$ , $\cos\dfrac{\pi}{12}$ និង $\tan\dfrac{\pi}{12}$

(b) $\cos^4\dfrac{\pi}{24} - \sin^4\dfrac{\pi}{24}$

(c) $\cos 36° - \cos 72°$

(d) $\sin 10° \sin 50° \sin 70°$ ។

## លំហាត់ ៤

សម្រួលកន្សោម $\sqrt{\sin^4 x + 4\cos^2 x} - \sqrt{\cos^4 x + 4\sin^2 x}$ ។

## លំហាត់ ៥

បង្ហាញថា $1 - \cot 23° = \dfrac{2}{1 - \cot 22°}$ ។

## លំហាត់ ៦

កំណត់ $x \in \left(0, \dfrac{\pi}{2}\right)$ បើគេដឹងថា $\dfrac{\sqrt{3}-1}{\sin x} + \dfrac{\sqrt{3}+1}{\cos x} = 4\sqrt{2}$ ។

**លំហាត់ ៧**

យក $\Re$ ជាសំណុំនៃគូ $(x, y)$បំពេញលក្ខខណ្ឌ $x^2 + y^2 \le 100$ និង $\sin(x+y) \ge 0$ ។ គណនាផ្ទៃតំណាង $\Re$ ។

**លំហាត់ ៨**

ចំពោះគ្រប់ត្រីកោណ $ABC$ បង្ហាញថា $\sin\frac{A}{2} \le \frac{a}{b+c}$ ។

**លំហាត់ ៩**

គេឲ្យ $I = \left[-\frac{\pi}{4}, \frac{\pi}{4}\right]$ និង $f$ ជាអនុវត្តន៍កំណត់លើ $[-1,1]$ដោយ $f(\sin 2x) = \sin x + \cos x$ ។ កំណត់ $f$ រួច ទាញរក $f(\tan^2 x)$ ចំពោះ $\forall x \in I$ ។

**លំហាត់ ១០**

យក $f_k(x) = \frac{1}{k}(\sin^k x + \cos^k x)$ចំពោះ $k = 1, 2, \dots, n$ ។

បង្ហាញថា $f_4(x) - f_6(x) = \frac{1}{12}$ , $\forall x \in \mathrm{IR}$ ។

**លំហាត់ ១១**

( AIME,2004 )

រង្វង់មួយមានកាំ 1 ឯកតា ត្រូវបានគេយកទៅដាក់ក្នុងចតុកោណកែង $ABCD$ មួយដែលមានទំហំ $15 \times 36$ ( គ្មានផ្នែកណានៃរង្វង់ស្ថិតនៅក្រៅចតុកោណ ) ។ កំណត់ប្រូបាប៊ីលីតេដែលរង្វង់មិនកាត់អង្កត់ទ្រូង $AC$ ។

**លំហាត់ ១២**

( AMC 12,1999 )

គេឲ្យត្រីកោណ $ABC$ មួយបំពេញលក្ខខណ្ឌ $3\sin A + 4\cos B = 6$

និង $4\sin B + 3\cos A = 1$ ។ គណនាមុំ $C$ ។

### លំហាត់ ១៣

បង្ហាញថា $\tan 3a - \tan 2a - \tan a = \tan 3a \tan 2a \tan a$

ចំពោះ $\forall a \neq \frac{k\pi}{2},\ k \in \mathbb{Z}$ ។

### លំហាត់ ១៤

គេឲ្យ $a$ , $b$ , $c$ , $d \in [0, \pi]$ បំពេញលក្ខខណ្ឌ

$\sin a + 7\sin b = 4(\sin c + 2\sin d)$ និង

$\cos a + 7\cos b = 4(\cos c + 2\cos d)$ ។

បង្ហាញថា $2\cos(a - d) = 7\cos(b - c)$ ។

### លំហាត់ ១៥

សរសេរ $\sin(x - y) + \sin(y - z) + \sin(z - x)$ ជាផលគុណកត្តា ។

### លំហាត់ ១៦

បង្ហាញថា $(4\cos^2 9^\circ - 3)(4\cos^2 27^\circ - 3) = \tan 9^\circ$ ។

### លំហាត់ ១៧

បង្ហាញថា $\left(1 + \frac{a}{\sin x}\right)\left(1 + \frac{b}{\cos x}\right) \geq \left(1 + \sqrt{2ab}\right)^2$ ចំពោះ $\forall a, b \geq 0$

និង $0 < x < \frac{\pi}{2}$ ។

### លំហាត់ ១៨

គេឲ្យត្រីកោណ $ABC$ បំពេញលក្ខខណ្ឌ $\sin A + \sin B + \sin C \leq 1$ ។

បង្ហាញថា $\min\{A + B, B + C, C + A\} < 30^\circ$ ។

## លំហាត់ ១៩

ចំពោះត្រីកោណ $ABC$ បង្ហាញថា

(a) $\tan\frac{A}{2}\tan\frac{B}{2}+\tan\frac{B}{2}\tan\frac{C}{2}+\tan\frac{C}{2}\tan\frac{A}{2}=1$

(b) $\tan\frac{A}{2}\tan\frac{B}{2}\tan\frac{C}{2}\le\frac{\sqrt{3}}{9}$ ។

## លំហាត់ ២០

យក $ABC$ ជាត្រីកោណមុំស្រួច ។ បង្ហាញថា

(a) $\tan A+\tan B+\tan C=\tan A\tan B\tan C$

(b) $\tan A\tan B\tan C\ge 3\sqrt{3}$ ។

## លំហាត់ ២១

គេឲ្យ $ABC$ ជាត្រីកោណមួយ ។

បង្ហាញថា $\cot A\cot B+\cot B\cot C+\cot C\cot A=1$ ។

ច្រាសមកវិញ បើ $x$, $y$, $z$ ជាចំនួនពិត បំពេញលក្ខខណ្ឌ $xy+yz+zx=1$ បង្ហាញថា មានត្រីកោណ $ABC$ បំពេញលក្ខខណ្ឌ $\cot A=x$, $\cot B=y$ និង $\cot C=z$ ។

## លំហាត់ ២២

គេឲ្យ $ABC$ ជាត្រីកោណមួយ ។

បង្ហាញថា $\sin^2\frac{A}{2}+\sin^2\frac{B}{2}+\sin^2\frac{C}{2}+2\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}=1$ ។

ច្រាសមកវិញ បើ $x$, $y$, $z$ ជាចំនួនពិតវិជ្ជមាន បំពេញលក្ខខណ្ឌ $x^2+y^2+z^2+2xyz=1$ បង្ហាញថា មានត្រីកោណ $ABC$ បំពេញលក្ខខណ្ឌ $x=\sin\frac{A}{2}$, $y=\sin\frac{B}{2}$ និង $z=\sin\frac{C}{2}$ ។

**លំហាត់ ២៣**

គេឲ្យ $ABC$ ជាត្រីកោណមួយ ។ បង្ហាញថា

(a) $\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}\le\frac{1}{8}$

(b) $\sin^2\frac{A}{2}+\sin^2\frac{B}{2}+\sin^2\frac{C}{2}\ge\frac{3}{4}$

(c) $\cos^2\frac{A}{2}+\cos^2\frac{B}{2}+\cos^2\frac{C}{2}\le\frac{9}{4}$

(d) $\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}\le\frac{3\sqrt{3}}{8}$

(e) $\csc\frac{A}{2}+\csc\frac{B}{2}+\csc\frac{C}{2}\ge 6$

**លំហាត់ ២៤**

ក្នុងត្រីកោណ $ABC$ បង្ហាញថា

(a) $\sin 2A+\sin 2B+\sin 2C=4\sin A\sin B\sin C$

(b) $\cos 2A+\cos 2B+\cos 2C=-1-4\cos A\cos B\cos C$

(c) $\sin^2 A+\sin^2 B+\sin^2 C=2+2\cos A\cos B\cos C$

(d) $\cos^2 A+\cos^2 B+\cos^2 C+2\cos A\cos B\cos C=1$ ។

ប្រាសមកវិញ បើ $x$ , $y$ , $z$ ជាចំនួនពិតវិជ្ជមានផ្ទៀងផ្ទាត់ $x^2+y^2+z^2+2xyz=1$ បង្ហាញថា មានត្រីកោណមុំស្រួច $ABC$ បំពេញលក្ខខណ្ឌ $x=\cos A,\ y=\cos B$ និង $z=\cos C$ ។

**លំហាត់ ២៥**

ក្នុងត្រីកោណ $ABC$ បង្ហាញថា

(a) $4R=\frac{abc}{[ABC]}$

(b) $2R^2\sin A\sin B\sin C=[ABC]$

(c) $2R\sin A\sin B\sin C=r(\sin A+\sin B+\sin C)$

(d) $r = 4R\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}$

(e) $a\cos A + b\cos B + c\cos C = \frac{abc}{2R^2}$ ។

## លំហាត់ ២៦

តាង $s$ ជាកន្លះបរិមាត្រនៃត្រីកោណ $ABC$ ។ បង្ហាញថា

(a) $s = 4R\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}$

(b) $s \le \frac{3\sqrt{3}}{2}R$ ។

## លំហាត់ ២៧

ក្នុងត្រីកោណ $ABC$ បង្ហាញថា

(a) $\cos A + \cos B + \cos C = 1 + 4\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}$

(b) $\cos A + \cos B + \cos C \le \frac{3}{2}$ ។

## លំហាត់ ២៨

ក្នុងត្រីកោណ $ABC$ បង្ហាញថា

(a) $\cos A\cos B\cos C \le \frac{1}{8}$

(b) $\sin A + \sin B + \sin C \le \frac{3\sqrt{3}}{8}$

(c) $\sin A\sin B\sin C \le \frac{3\sqrt{3}}{8}$

(d) $\cos^2 A + \cos^2 B + \cos^2 C \ge \frac{3}{4}$

(e) $\sin^2 A + \sin^2 B + \sin^2 C \le \frac{9}{4}$

(f) $\cos 2A + \cos 2B + \cos 2C \geq -\frac{3}{2}$

(g) $\sin 2A + \sin 2B + \sin 2C \leq \frac{3\sqrt{3}}{2}$ ។

## លំហាត់ ២៩

បង្ហាញថា $\frac{\tan 3x}{\tan x} = \tan\left(\frac{\pi}{3} - x\right)\tan\left(\frac{\pi}{3} + x\right)$ ចំពោះ $\forall x \neq \frac{k\pi}{6}$ , $k \in \mathbb{Z}$ ។

## លំហាត់ ៣០

គេឲ្យ $(1+\tan 1°)(1+\tan 2°)\ldots(1+\tan 45°) = 2^n$ ។ គណនា $n$ ។

## លំហាត់ ៣១

ក្នុងតម្រុយអរតូណារមេគេមានចំណុច $A(0,0)$ និង $B(b,2)$ ។ យក $ABCDEF$ ជាឆកោណនិយ័តប៉ោងបំពេញលក្ខខណ្ឌ $\angle FAB = 120°$ , $AB \parallel DE$ , $BC \parallel EF$ , $CD \parallel FA$ និង អរដោនេ $y$ នៃកំពូលនីមួយៗរបស់វាខុសពីធាតុនៃសំណុំ $\{0,2,4,6,8,10\}$ ។ ក្រឡាផ្ទៃនៃឆកោណនេះអាចត្រូវបានសរសេរជារាង $m\sqrt{n}$ ដែល $m$ និង $n$ ជាចំនួនគត់វិជ្ជមាន ហើយ $n$ ចែកមិនដាច់នឹងការេនៃចំនួនបឋម ។ គណនា $m+n$ ។

## លំហាត់ ៣២

បើសិនជា Casio របស់អ្នកខូចប៊ូតុងសម្រាប់គណនាចម្រាសនៃចំនួនមួយ បញ្ជាក់ថាអ្នកនៅតែអាចគណនាចម្រាសនៃចំនួនមួយដោយប្រើតែបណ្ដាក់នៃប៊ូតុងត្រីកោណមាត្រ ដូចជា $\sin$ , $\cos$ , $\tan$ , $\sin^{-1}$ , $\cos^{-1}$ និង $\tan^{-1}$ ។

## លំហាត់ ៣៣

គេឲ្យត្រីកោណ $ABC$ បំពេញលក្ខខណ្ឌ $A - B = 120°$ និង $R = 8r$ ។ គណនា $\cos C$ ។

### លំហាត់ ៣៤

ចំពោះគ្រប់ត្រីកោណ $ABC$ បង្ហាញថា $\frac{a-b}{a+b}=\tan\left(\frac{A-B}{2}\right)\tan\frac{C}{2}$ ។

### លំហាត់ ៣៥

គេឲ្យត្រីកោណ $ABC$ មួយផ្ទៀងផ្ទាត់ $\frac{a}{b}=2+\sqrt{3}$ និង $\angle C=60^\circ$ ។

គណនា $\angle A$ និង $\angle B$ ។

### លំហាត់ ៣៦

គេឲ្យ $a$ , $b$ , $c\neq -1$ និង $1$ បំពេញលក្ខខណ្ឌ $a+b+c=abc$ ។

បង្ហាញថា $\frac{a}{1-a^2}+\frac{b}{1-b^2}+\frac{c}{1-c^2}=\frac{4abc}{(1-a^2)(1-b^2)(1-c^2)}$ ។

### លំហាត់ ៣៧

បង្ហាញថា ត្រីកោណ $ABC$ ជាត្រីកោណសមបាត លុះត្រាតែ

$a\cos B+b\cos C+c\cos A=\frac{a+b+c}{2}$ ។

### លំហាត់ ៣៨

គណនា $\cos a\cos 2a\cos 3a\ldots\cos 999a$ ចំពោះ $a=\frac{2\pi}{1999}$ ។

### លំហាត់ ៣៩

កំណត់តម្លៃតូចបំផុតនៃ $\frac{\sec^4\alpha}{\tan^2\beta}+\frac{\sec^4\beta}{\tan^2\alpha}$ ចំពោះ $\forall\alpha$ , $\beta\neq\frac{k\pi}{2}$ , $k\in \mathbb{Z}$ ។

**លំហាត់ ៤០**

រកគ្រប់គូ $(x,y)\in\left(0,\frac{\pi}{2}\right)^2$ បើគេដឹងថា $\frac{(\sin x)^{2y}}{(\cos x)^{\frac{y^2}{2}}}+\frac{(\cos x)^{2y}}{(\sin x)^{\frac{y^2}{2}}}=\sin 2x$ ។

**លំហាត់ ៤១**

បង្ហាញថា $\cos 1^\circ$ ជាចំនួនអសនិទាន ។

**លំហាត់ ៤២**

រកតម្លៃអតិបរមានៃ $S=(1-x_1)(1-y_1)+(1-x_2)(1-y_2)$ បើគេដឹងថា៖ $x_1^2+x_2^2=y_1^2+y_2^2=c^2$ ។

**លំហាត់ ៤៣**

បង្ហញថា $\frac{\sin^3 a}{\sin b}+\frac{\cos^3 a}{\cos b}\geq \sec(a-b)$ ចំពោះ $0<a\,,\ b<\frac{\pi}{2}$ ។

**លំហាត់ ៤៤**

គេឲ្យ $\sin\alpha\cos\beta=-\frac{1}{2}$ ។ គណនា $\cos\alpha\sin\beta$ ។

**លំហាត់ ៤៥**

គេឲ្យ $a$ , $b$ , $c$ ជាចំនួនពិត ។ បង្ហាញថា
$(ab+bc+ca-1)^2\leq (a^2+1)(b^2+1)(c^2+1)$ ។

**លំហាត់ ៤៦**

បង្ហាញថា $(\sin x+a\cos x)(\sin x+b\cos x)\leq 1+\left(\frac{a+b}{2}\right)^2$ ( * )។

## លំហាត់ ៤៧

បង្ហាញថា $\sum_{i=1}^{n}|\sin a_i| + \left|\cos\left(\sum_{i=1}^{n} a_i\right)\right| \geq 1$ ចំពោះ $\forall n \in \mathrm{IN}$ ។

## លំហាត់ ៤៨

( Russia 2003, By Nazar Agakhanov )

រកគ្រប់មុំ $\alpha$ ដើម្បីឲ្យសំណុំមានបីធាតុ $S = \{\sin\alpha, \sin 2\alpha, \sin 3\alpha\}$ ស្មើនឹងសំណុំ $T = \{\cos\alpha, \cos 2\alpha, \cos 3\alpha\}$ ។

## លំហាត់ ៤៩

យក $\{T_n(x)\}_{n=0}^{\infty}$ ជាស្វ៊ីតនៃពហុធាបំពេញលក្ខខណ្ឌ៖ $T_0(x) = 1, T_1(x) = x$
និង $T_{i+1} = 2xT_i(x) - T_{i-1}(x)$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $i$ ។
ពហុធា $T_n(x)$ ហៅថា ពហុធា *Chebyshev* ទី $n$ ។
ក/ បង្ហាញថា៖ $T_{2n+1}(x)$ និង $T_{2n}(x)$ ជាអនុគមន៍សេស និង គូរៀងគ្នា
ខ/ បង្ហាញថា៖ $T_{n+1}(x) > T_n(x) > 1$ ចំពោះចំនួនពិត $x > 1$
គ/ បង្ហាញថា៖ $T_n(\cos\theta) = \cos n\theta$ ចំពោះចំនួនគត់មិនអវិជ្ជមាន $n$
ឃ/ រកគ្រប់រឹសនៃពហុធា $T_n(x)$
ង/ រកគ្រប់រឹសនៃពហុធា $P_n(x) = T_n(x) - 1$ ។

## លំហាត់ ៥០

គេឲ្យត្រីកោណ $ABC$ ផ្ទៀងផ្ទាត់ $\angle BAC = 40°$ និង $\angle ABC = 60°$ ។
$D$ , $E$ ស្ថិតនៅលើជ្រុង $AB$ , $AC$ រៀងគ្នាដែល $\angle CBD = 40°$ និង $\angle BCE = 70°$ ។ អង្កត់ $[BD]$ និង $[CE]$ ប្រសព្វគ្នាត្រង់ $F$ ។ បង្ហាញថា $AF \perp BC$ ។

## លំហាត់ ៥១

( IMO,1991 )

យក $S$ ជាចំណុចមួយនៅក្នុងត្រីកោណ $ABC$ ។ បង្ហាញថា យ៉ាងហោចណាស់មួយក្នុងចំណោមមុំ $\angle SAB$ , $\angle SBC$ និង $\angle SCA \le 30^\circ$ ។

## លំហាត់ ៥២

គេឲ្យ $a = \frac{\pi}{7}$ ។

(a) បង្ហាញថា $\sin^2 3a - \sin^2 a = \sin 2a \sin 3a$

(b) បង្ហាញថា $\csc a = \csc 2a + \csc 4a$

(c) គណនា $\cos a - \cos 2a + \cos 3a$

(d) បង្ហាញថា $\cos a$ ជាឫសមួយនៃសមីការ $8x^3 + 4x^2 - 4x - 1 = 0$

(e) បង្ហាញថា $\cos a$ ជាចំនួនអសនិទាន

(f) គណនា $\tan a \tan 2a \tan 3a$

(g) គណនា $\tan^2 a + \tan^2 2a + \tan^2 3a$

(h) គណនា $\tan^2 a \tan^2 2a + \tan^2 2a \tan^2 3a + \tan^2 3a \tan^2 a$

(i) គណនា $\cot^2 a + \cot^2 2a + \cot^2 3a$

## លំហាត់ ៥៣

ក/ រកចំនួនគត់វិជ្ជមាន $n$ តូចបំផុតដែលបំពេញលក្ខខណ្ឌ

$$\frac{1}{\sin 45^\circ \sin 46^\circ} + \frac{1}{\sin 47^\circ \sin 48^\circ} + \dots + \frac{1}{\sin 133^\circ \sin 134^\circ} = \frac{1}{\sin n^\circ}$$ ។

ខ/ ស្រាយបញ្ជាក់ថា

$$\frac{1}{\sin 1^\circ \sin 2^\circ} + \frac{1}{\sin 2^\circ \sin 3^\circ} + \dots + \frac{1}{\sin 89^\circ \sin 90^\circ} = \frac{\cos 1^\circ}{\sin^2 1^\circ}$$ ។

## លំហាត់ ៥៤

(China,2001)

យក $ABC$ ជាត្រីកោណដែលមានរង្វាស់ជ្រុង $AB = c$ , $AC = b$ និង $BC = a$ ។ ចំពោះ $x$ ជាចំនួនពិតមិនអវិជ្ជមាន ស្រាយបញ្ជាក់ថា

$a^x\cos A+b^x\cos B+c^x\cos C\ge\frac{1}{2}\left(a^x+b^x+c^x\right)$ ។

## លំហាត់ ៥៥

គេឲ្យ $x$ , $y$ , $z$ ជាចំនួនពិតវិជ្ជមាន ។ បង្ហាញថា

(a) $\frac{x}{\sqrt{1+x^2}}+\frac{y}{\sqrt{1+y^2}}+\frac{z}{\sqrt{1+z^2}}\le\frac{3\sqrt{3}}{2}$

(b) $\frac{x}{1-x^2}+\frac{y}{1-y^2}+\frac{z}{1-z^2}\ge\frac{3\sqrt{3}}{2}$ បើគេដឹងថា $0<x\,,\ y\,,\ z<1$ និង $x+y+z=xyz$ ។

## លំហាត់ ៥៦

(China,1997)

គេឲ្យ $x$ , $y$ , $z$ បំពេញលក្ខខណ្ឌ $x\ge y\ge z\ge\frac{\pi}{12}$ និង $x+y+z=\frac{\pi}{2}$ ។ កំណត់តម្លៃអតិបរមា និង អប្បបរមានៃ $\cos x\sin y\cos z$ ។

## លំហាត់ ៥៧

គេឲ្យ $ABC$ ជាត្រីកោណមុំស្រួច ។ ចំពោះ $n=1,\ 2\ ,\ 3$ គេតាង

$x_n=2^{n-3}\left(\cos^n A+\cos^n B+\cos^n C\right)+\cos A\cos B\cos C$ ។

បង្ហាញថា $x_1+x_2+x_3\ge\frac{3}{2}$ ។

## លំហាត់ ៥៨

រកផលបូកនៃគ្រប់តម្លៃ $x$ លើ $[0,2\pi]$ បើគេដឹងថា $3\cot^2 x+8\cot x+3=0$ ។

## លំហាត់ ៥៩

គេឲ្យត្រីកោណ $ABC$ ជាត្រីកោណមុំស្រួចមានក្រឡាផ្ទៃ $K$ ។ បង្ហាញថា

$$\sqrt{a^2b^2-4K^2}+\sqrt{b^2c^2-4K^2}+\sqrt{c^2a^2-4K^2}=\frac{a^2+b^2+c^2}{2}$$ ។

## លំហាត់ ៦០

គណនា $S_n = C_n^1 \sin a + C_n^2 \sin 2a + ... + C_n^n \sin na$

និង $T_n = C_n^1 \cos a + C_n^2 \cos 2a + ... + C_n^n \cos na$ ។

## លំហាត់ ៦១

កំណត់តម្លៃតូចបំផុតនៃ $|\sin x + \cos x + \tan x + \cot x + \sec x + \csc x|$

ចំពោះគ្រប់ចំនួនពិត $x$ ។

## លំហាត់ ៦២

( Belarus,1999 )

គេឲ្យស្វ៊ីតនៃចំនួនពិតពីរ គឺ $x_1$, $x_2$, … , $x_n$ និង $y_1$, $y_2$, … , $y_n$ ផ្ទៀងផ្ទាត់

លក្ខខណ្ឌ $x_1 = y_1 = \sqrt{3}$, $x_{n+1} = x_n + \sqrt{1+x_n^2}$ និង $y_{n+1} = \dfrac{y_n}{\sqrt{1+y_n^2}}$

ចំពោះគ្រប់ $n \geq 1$ ។ បង្ហាញថា $2 < x_n y_n < 3$ ។

## លំហាត់ ៦៣

គេឲ្យ $a$, $b$, $c$ ជាចំនួនពិតផ្ទៀងផ្ទាត់ $\sin a + \sin b + \sin c \geq \dfrac{3}{2}$ ។

បង្ហាញថា $\sin\left(a-\dfrac{\pi}{6}\right)+\sin\left(b-\dfrac{\pi}{6}\right)+\sin\left(c-\dfrac{\pi}{6}\right)\geq 0$ ។

## លំហាត់ ៦៤

ឧបមថា បួនចំនួនត្រូវបានជ្រើសចេញពីចន្លោះ $\left[\dfrac{\sqrt{2}-\sqrt{6}}{4}, \dfrac{\sqrt{2}+\sqrt{6}}{4}\right]$ ។

បង្ហាញថា មានពីរក្នុងចំណោមបួនចំនួននោះ( សន្មតថា $a$, $b$ ) បំពេញលក្ខខណ្ឌ

$$\left|a\sqrt{4-b^2}-b\sqrt{4-a^2}\right|\le 2$$ ។

## លំហាត់ ៦៥

គេឲ្យ $a$ , $b$ ជាចំនួនពិតក្នុងចន្លោះ $\left[0,\frac{\pi}{2}\right]$ ។ បង្ហាញថា

$\sin^6 a+3\sin^2 a\cos^2 b+\cos^6 b=1$ លុះត្រាតែ $a=b$ ។

## លំហាត់ ៦៦

គេឲ្យ $x$ , $y$ , $z$ ជាចំនួនពិតបំពេញលក្ខខណ្ឌ $0<x<y<z<\frac{\pi}{2}$ ។

បង្ហាញថា $\frac{\pi}{2}+2\sin x\cos y+2\sin y\cos z\ge \sin 2x+\sin 2y+\sin 2z$ ។

## លំហាត់ ៦៧

គេឲ្យ $ABCDE$ ជាពហុកោណចារឹកក្នុងរង្វង់ ។ បង្ហាញថា បើ $r_{ABC}=r_{AED}$ , $r_{ABD}=r_{AEC}$ នោះ គេបាន $ABC$ និង $AED$ ជាត្រីកោណប៉ុនគ្នា ។

## លំហាត់ ៦៨

គ្មានមុំណាមួយនៃត្រីកោណ $ABC$ មានរង្វាស់ធំជាង $120°$ ។ បង្ហាញថា

$$\frac{\cos A+\cos B-\cos C}{\cos A+\sin B-\sin C}>-\frac{\sqrt{3}}{2}$$ ។

## លំហាត់ ៦៩

( USAMO,2002 )

គេឲ្យត្រីកោណ $ABC$ បំពេញលក្ខខណ្ឌ $\left(\cot\frac{A}{2}\right)^2+\left(\cot\frac{B}{2}\right)^2+\left(\cot\frac{C}{2}\right)^2=\left(\frac{6s}{7r}\right)^2$ ( * ) ដែល $s$ និង $r$ តាងឲ្យកន្លះ

បរិមាត្រ និង កាំរង្វង់ចារឹកក្នុងត្រីកោណ $ABC$ រៀងគ្នា ។ បង្ហាញថា ត្រីកោណ $ABC$ ដូចត្រីកោណ $T$ ដែលមានរង្វាស់ជ្រុងទាំងអស់ជាចំនួនគត់វិជ្ជមាន និង ជាបីចំនួនបឋមរវាងគ្នា ដែលចំនួនគត់វិជ្ជមានទាំងបីនេះត្រូវកំណត់ ។

## លំហាត់ ៧០

( USAMO,1996 )

បង្ហាញថា មធ្យមនៃចំនួន $2\sin 2^\circ$ , $4\sin 4^\circ$ , … , $180\sin 180^\circ$ ស្មើនឹង $\cot 1^\circ$ ។

## លំហាត់ ៧១

គេឲ្យ $ABC$ ជាត្រីកោណមុំស្រួច ។ បង្ហាញថា

$$\cot^3 A+\cot^3 B+\cot^3 C+6\cot A\cot B\cot C \geq \cot A+\cot B+\cot C \quad (*)$$ ។

## លំហាត់ ៧២

( Turkey,1998 )

គេឲ្យ $(a_n)$ ជាស្វ៊ីតនៃចំនួនពិតកំណត់ដោយ $a_1=t$ , $a_{n+1}=4a_n(1-a_n)$ ចំពោះ $n\geq 1$ ។ តើមានតម្លៃ $t$ ផ្សេងគ្នាចំនួនប៉ុន្មានផ្ទៀងផ្ទាត់សមីការ $a_{1998}=0$ ។

## លំហាត់ ៧៣

យក $P$ ជាចំណុចក្នុងមួយនៃត្រីកោណ $ABC$ បំពេញលក្ខខណ្ឌ $\angle PAB=10^\circ$ , $\angle PBA=20^\circ$ , $\angle PCA=30^\circ$ និង $\angle PAC=40^\circ$ ។ បង្ហាញថា ត្រីកោណ $ABC$ ជាត្រីកោណសមបាត ។

## លំហាត់ ៧៤

គេឲ្យ $a_0=\sqrt{2}+\sqrt{3}+\sqrt{6}$ និង $a_{n+1}=\dfrac{a_n^2-5}{2(a_n+2)}$ ចំពោះគ្រប់ $n>0$ ។

បង្ហាញថា $a_n=\cot\left(\dfrac{2^{n-3}\pi}{3}\right)-2$ ចំពោះគ្រប់ $n\geq 0$ ។

## លំហាត់ ៧៥

(APMC,1982)

ចំពោះ $n \in \mathrm{IN} - \{0,1\}$ បង្ហាញថា

$$\prod_{k=1}^{n} \tan\left[\frac{\pi}{3}\left(1+\frac{3^k}{3^n-1}\right)\right] = \prod_{k=1}^{n} \cot\left[\frac{\pi}{3}\left(1-\frac{3^k}{3^n-1}\right)\right] \quad (*)$$ ។

## លំហាត់ ៧៦

(China,1999)

គេឲ្យពហុធា $P_2(x) = x^2 - 2$ ។ កំណត់គ្រប់ស្វ៊ីតពហុធា $\{P_k(x)\}_{k=0}^{\infty}$ បើ $P_k(x)$ ជាពហុធាម៉ូនិច (Monic) មានដឺក្រេ $k$ និង $P_i(P_j(x)) = P_j(P_i(x))$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $i$ , $j$ ។

## លំហាត់ ៧៧

(China,2000)

ក្នុងត្រីកោណ $ABC$ គេមាន $a \le b \le c$ ។ កំណត់លក្ខខណ្ឌនៃមុំ $C$ ដើម្បីកន្សោម $a+b-2R-2r$ ជាចំនួនវិជ្ជមាន អវិជ្ជមាន និង សូន្យ ។

## លំហាត់ ៧៨

យក $D$ , $E$ , $F$ ជាចំណុចនៅលើជ្រុង $BC$ , $CA$ , $AB$ នៃត្រីកោណ $ABC$ រៀងគ្នា ។ បើគេដឹងថា $DC+CE = EA+AF = FB+BD$ បង្ហាញថា

$$DE+EF+FD \ge \frac{1}{2}(AB+BC+CA)$$ ។

## លំហាត់ ៧៩

ចំពោះ $a$ , $b$ ជាចំនួនពិតវិជ្ជមាន បង្ហាញថា $\frac{1}{\sqrt{1+a^2}} + \frac{1}{\sqrt{1+b^2}} \ge \frac{2}{\sqrt{1+ab}}$

បើ (a) $0 < a,b \le 1$ រឺ (b) $ab \ge 3$ ។

## លំហាត់ ៨០

( China,1998 )

គេឲ្យ $ABC$ ជាត្រីកោណមិនមានមុំទាល បំពេញលក្ខខណ្ឌ $AB > AC$ , $\angle B = 45^\circ$ ។ យក $O$ និង $I$ ជាផ្ចិតរង្វង់ចារឹកក្រៅ និង ចារឹកក្នុងរៀងគ្នានៃត្រីកោណនេះ ។ឧបមាថា $\sqrt{2}OI = AB - AC$ ។ គណនា $\sin A$ ។

## លំហាត់ ៨១

គេឲ្យ $n$ ជាចំនួនគត់វិជ្ជមាន ។ កំណត់ចំនួនពិត $a_0$ និង $a_{k,l}$ , $1 \le l < k \le n$ បំពេញលក្ខខណ្ឌ $\dfrac{\sin^2 nx}{\sin^2 x} = a_0 + \sum\limits_{1\le l<k\le n} a_{l,k}\cos 2(k-l)x$ ( * ) ។

## លំហាត់ ៨២

( USAMO,2000 )

យក $S$ ជាសំណុំនៃត្រីកោណ $ABC$ បំពេញលក្ខខណ្ឌ

$5\left(\dfrac{1}{AP}+\dfrac{1}{BQ}+\dfrac{1}{CR}\right)-\dfrac{3}{\min\{AP,BQ,CR\}}=\dfrac{6}{r}$ ដែល $r$ ជាកាំរង្វង់ចារឹកក្នុងត្រីកោណ $ABC$ និង $P$ , $Q$ , $R$ ជាចំណុចប៉ះរវាងរង្វង់ចារឹកក្នុងនឹងជ្រុង $AB$ , $BC$ , $CA$ នៃត្រីកោណ $ABC$ រៀងគ្នា ។ បង្ហាញថា ត្រីកោណទាំងអស់នៃសំណុំ $S$ ជាត្រីកោណសមបាត និង ដូចគ្នា ។

## លំហាត់ ៨៣

( TST,2003 )

គេឲ្យ $a$ , $b$ , $c$ ជាចំនួនពិតនៃចន្លោះ $\left(0,\dfrac{\pi}{2}\right)$ ។ បង្ហាញថា

$$\frac{\sin a\sin(a-b)\sin(a-c)}{\sin(b+c)}+\frac{\sin b\sin(b-c)\sin(b-a)}{\sin(c+a)}$$
$$+\frac{\sin c\sin(c-a)\sin(c-b)}{\sin(a+b)}\ge 0 \quad (\ *\ )។$$

## លំហាត់ ៨៤

(TST,2002)

ចំពោះ គ្រប់ត្រីកោណ $ABC$ បង្ហាញថា $\sin\frac{3A}{2}+\sin\frac{3B}{2}+\sin\frac{3C}{2}$
$\le\cos\left(\frac{A-B}{2}\right)+\cos\left(\frac{B-C}{2}\right)+\cos\left(\frac{C-A}{2}\right)$ ( * )។

## លំហាត់ ៨៥

គេឲ្យ $x_1,\ x_2,\dots,\ x_n,\ n\ge 2$ ជា $n$ ចំនួនផ្សេងគ្នានៃចន្លោះ $[-1,1]$។
បង្ហាញថា $\frac{1}{t_1}+\frac{1}{t_2}+\dots+\frac{1}{t_n}\ge 2^{n-2}$ ដែល $t_i=\prod_{j\ne i}\left|x_j-x_i\right|$ ។

## លំហាត់ ៨៦

(St.Petersburg, 2001)

គេឲ្យ $x_1,\ x_2,\dots,x_{10}$ ជាចំនួនពិតក្នុងចន្លោះ $\left[0,\frac{\pi}{2}\right]$ បំពេញលក្ខខណ្ឌ
$\sin^2 x_1+\sin^2 x_2+\dots+\sin^2 x_{10}=1$ ។ បង្ហាញថា
$3(\sin x_1+\sin x_2+\dots+\sin x_{10})\le\cos x_1+\cos x_2+\dots+\cos x_{10}$ ។

## លំហាត់ ៨៧

(IMO Shortlist,2001)

គេឲ្យ $x_1,\ x_2,\dots,\ x_n$ ជាចំនួនពិត ។ បង្ហាញថា
$$\frac{x_1}{1+x_1^2}+\frac{x_2}{1+x_1^2+x_2^2}+\dots+\frac{x_n}{1+x_1^2+x_2^2\dots+x_n^2}<\sqrt{n}$$ ។

## លំហាត់ ៨៨

(USAMO,1998)

គេឲ្យ $a_0$, $a_1$, … , $a_n$ ជាចំនួនពិតនៃចន្លោះ $\left(0,\frac{\pi}{2}\right)$ បំពេញលក្ខខណ្ឌ

$\tan\left(a_0-\frac{\pi}{4}\right)+\tan\left(a_1-\frac{\pi}{4}\right)+\ldots+\tan\left(a_n-\frac{\pi}{4}\right)\geq n-1$ ។

បង្ហាញថា $\tan a_0 \tan a_1 \ldots \tan a_n \geq n^{n+1}$ ។

## លំហាត់ ៨៩

( MOSP,2001 )

កំណត់គ្រប់ត្រីធាតុ $(a,b,c)$ដែលផ្ទៀងផ្ទាត់សមីការ $a^2-2b^2=1$, $2b^2-3c^2=1$និង $ab+bc+ca=1$ ។

## លំហាត់ ៩០

គេឲ្យ $n$ ជាចំនួនគត់វិជ្ជមាន និង $0<\theta_i<90^\circ$ , $i=\overline{1,n}$ ផ្ទៀងផ្ទាត់ $\cos^2\theta_1+\cos^2\theta_2+\ldots+\cos^2\theta_n=1$ ។ បង្ហាញថា

$\tan\theta_1+\tan\theta_2+\ldots+\tan\theta_n\geq(n-1)(\cot\theta_1+\cot\theta_2+\ldots+\cot\theta_n)$ ។

## លំហាត់ ៩១

មួយក្នុងចំណោមវិសមភាព $(\sin x)^{\sin x}<(\cos x)^{\cos x}$

និង $(\sin x)^{\sin x}>(\cos x)^{\cos x}$ ពិត ចំពោះ $\forall x:\ 0<x<\frac{\pi}{4}$ ។

បញ្ជាក់ចម្លើយរបស់អ្នកដោយការស្រាយបញ្ជាក់ ។

## លំហាត់ ៩២

គេឲ្យ $k$ ជាចំនួនគត់វិជ្ជមាន ។ បង្ហាញថា $\sqrt{k+1}-\sqrt{k}$ មិនមែនជាផ្នែកពិតនៃចំនួនកុំផ្លិច $z$ ដែល $z^n=1$, $n\in \mathrm{IN}$ ។

## លំហាត់ ៩៣

យក $A_1A_2A_3$ ជាត្រីកោណមុំស្រួច និង $B_1$, $B_2$, $B_3$ ជាចំណុចនៅលើជ្រុង $A_2A_3$,

$A_3A_1$ , $A_1A_2$ រៀងគ្នា ។ បង្ហាញថា $2(b_1\cos A_1 + b_2\cos A_2 + b_3\cos A_3)$
$\geq a_1\cos A_1 + a_2\cos A_2 + a_3\cos A_3$ ( * ) ដែល $a_i = A_{i+1}A_{i+2}$ និង
$b_i = B_{i+1}B_{i+2}$ ចំពោះ $i = 1$ , 2 , 3 ( ក្នុងនោះ $x_{i+3} = x_i$ ) ។

## លំហាត់ ៩៤

គេឲ្យ $ABC$ ជាត្រីកោណមួយ, $x$ , $y$ , $z$ ជាចំនួនពិត និង $n$ ជាចំនួនគត់វិជ្ជមាន ។
បង្ហាញថា

(a) $x^2 + y^2 + z^2 \geq 2yz\cos A + 2zx\cos B + 2xy\cos C$

(b) $x^2 + y^2 + z^2 \geq 2(-1)^n(yz\cos nA + zx\cos nB + xy\cos nC)$

(c) $yza^2 + zxb^2 + xyc^2 \leq R^2(x+y+z)^2$

(d) $xa^2 + yb^2 + zc^2 \geq 4[ABC]\sqrt{xy + yz + zx}$ ។

## លំហាត់ ៩៥

( USAMO,2004 )

គេឲ្យ $\omega$ ជារង្វង់ចារឹកក្នុងចតុកោណ $ABCD$ ។ យក $I$ ជាផ្ចិតនៃ $\omega$ ។
ឧបមថា $(AI + DI)^2 + (BI + CI)^2 = (AB + CD)^2$ ។
បង្ហាញថា $ABCD$ ជាចតុកោណព្នាយសមបាត ។

## លំហាត់ ៩៦

( USAMO,2001 )

គេឲ្យ $a$ , $b$ , $c$ ជាចំនួនពិតមិនអវិជ្ជមានផ្ទៀងផ្ទាត់ $a^2 + b^2 + c^2 + abc = 4$ ។
បង្ហាញថា $0 \leq ab + bc + ca - abc \leq 2$ ។

## លំហាត់ ៩៧

គេឲ្យ $s$ , $t$ , $u$ , $v$ ជាចំនួនពិតវិជ្ជមានក្នុងចន្លោះ $\left(0, \frac{\pi}{2}\right)$ បំពេញលក្ខខណ្ឌ
$s + t + u + v = \pi$ ។ បង្ហាញថា

$$\frac{\sqrt{2}\sin s-1}{\cos s}+\frac{\sqrt{2}\sin t-1}{\cos t}+\frac{\sqrt{2}\sin u-1}{\cos u}+\frac{\sqrt{2}\sin v-1}{\cos v}\geq 0$$ ។

## លំហាត់ ៩៨

( USAMO,1995 )

ឧបមាថា ម៉ាស៊ីនគិតលេខមួយខូច ហើយប៊ូតុងដែលអាចប្រើប្រាស់បានមានតែប៊ូតុង $\sin$ , $\cos$ , $\tan$ , $\sin^{-1}$ , $\cos^{-1}$ និង $\tan^{-1}$ ។ អេក្រង់ដំបូងបង្ហាញលេខ $0$ ។ យក $q$ ជាចំនួនសនិទានវិជ្ជមានណាមួយ ។ បង្ហាញថា គេអាចបង្ហាញចំនួន $q$ នេះលើអេក្រង់ដោយប្រើតែប៊ូតុងខាងលើ បើគេសន្មតថាម៉ាស៊ីនគិតលេខនេះមានសមត្ថភាពគិតលេខបានច្រើនខ្ទង់ក្រោយក្បៀស(មិនកំណត់) និង តួលេខទាំងអស់គិតជារ៉ាដ្យង់។

## លំហាត់ ៩៩

គេឲ្យ $ABC$ ជាត្រីកោណមុំស្រួច ។ បង្ហាញថា

$$(\sin 2B+\sin 2C)^2\sin A+(\sin 2C+\sin 2A)^2\sin B$$
$$+(\sin 2A+\sin 2B)^2\sin C\leq 12\sin A\sin B\sin C \quad (*)$$ ។

## លំហាត់ ១០០

( MOSP,2000 )

គេឲ្យ $ABC$ ជាត្រីកោណមុំស្រួច ។ បង្ហាញថា

$$\left(\frac{\cos A}{\cos B}\right)^2+\left(\frac{\cos B}{\cos C}\right)^2+\left(\frac{\cos C}{\cos A}\right)^2+8\cos A\cos B\cos C\geq 4 \ (*)$$ ។

## លំហាត់ ១០១

ចំពោះគ្រប់ចំនួនពិត $x$ និង ចំនួនគត់វិជ្ជមាន $n$ បង្ហាញថា $\left|\sum_{k=1}^{n}\frac{\sin kx}{x}\right|\leq 2\sqrt{\pi}$ ។

# ជំពូក 3

# ដំណោះស្រាយ

## លំហាត់ ១

គេឲ្យ $\sec x - \tan x = 2$ ។ គណនា $\sec x + \tan x$ ។

**ចម្លើយ**

យើងមាន $1 + \tan^2 x = \sec^2 x \Rightarrow \sec^2 x - \tan^2 x = 1$

$$\Rightarrow (\sec x - \tan x)(\sec x + \tan x) = 1$$

$$\Rightarrow \sec x + \tan x = \frac{1}{\sec x + \tan x} = \frac{1}{2}$$

## លំហាត់ ២

គេឲ្យ $0° < \theta < 45°$ ។ តម្រៀប $t_1 = (\tan\theta)^{\tan\theta}$ , $t_2 = (\tan\theta)^{\cot\theta}$ , $t_3 = (\cot\theta)^{\tan\theta}$ , $t_4 = (\cot\theta)^{\cot\theta}$ តាមលំដាប់ចុះ ។

**ចម្លើយ**

ចំពោះ $0° < \theta < 45°$ គេបាន $0 < \tan\theta < 1 < \cot\theta$

$y = a^x$ ជាអនុគមន៍ចុះចំពោះ $0 < a < 1$ និង ជាអនុគមន៍កើនចំពោះ $a > 1$

គេបាន $t_1 = (\tan\theta)^{\tan\theta} > t_2 = (\tan\theta)^{\cot\theta}$

និង $t_4 = (\cot\theta)^{\cot\theta} > t_3 = (\cot\theta)^{\tan\theta}$

ម៉្យាងទៀត $t_1 = (\tan\theta)^{\tan\theta} < 1$ និង $t_3 = (\cot\theta)^{\tan\theta} > 1 \Rightarrow t_1 < t_3$

ហេតុនេះ $t_4 > t_3 > t_1 > t_2$

## លំហាត់ ៣

គណនា

(a) $\sin\frac{\pi}{12}$ , $\cos\frac{\pi}{12}$ និង $\tan\frac{\pi}{12}$

(b) $\cos^4\frac{\pi}{24} - \sin^4\frac{\pi}{24}$

(c) $\cos 36° - \cos 72°$

(d) $\sin 10° \sin 50° \sin 70°$ ។

**ចម្លើយ**

(a) យើងមាន $\sin\frac{\pi}{12}=\sin\left(\frac{\pi}{3}-\frac{\pi}{4}\right)=\sin\frac{\pi}{3}\cos\frac{\pi}{4}-\sin\frac{\pi}{4}\cos\frac{\pi}{3}$

$$=\left(\frac{\sqrt{3}}{2}\right)\left(\frac{\sqrt{2}}{2}\right)-\left(\frac{\sqrt{2}}{2}\right)\left(\frac{1}{2}\right)=\frac{\sqrt{6}-\sqrt{2}}{2}$$

ដូចគ្នា គេបាន $\cos\frac{\pi}{12}=\frac{\sqrt{6}+\sqrt{2}}{2}$

យើងបាន $\tan\frac{\pi}{12}=\dfrac{\frac{\sqrt{6}-\sqrt{2}}{2}}{\frac{\sqrt{6}+\sqrt{2}}{2}}=2-\sqrt{3}$

(b) $\cos^4\frac{\pi}{24}-\sin^4\frac{\pi}{24}=\left(\cos^2\frac{\pi}{24}-\sin^2\frac{\pi}{24}\right)\left(\cos^2\frac{\pi}{24}+\sin^2\frac{\pi}{24}\right)$

$$=\cos\frac{\pi}{12}=\frac{\sqrt{6}+\sqrt{2}}{2}$$

(c) $\cos 36^\circ-\cos 72^\circ=\frac{(\cos 36^\circ-\cos 72^\circ)(\cos 36^\circ+\cos 72^\circ)}{\cos 36^\circ+\cos 72^\circ}$

$$=\frac{\cos^2 36^\circ-\cos^2 72^\circ}{\cos 36^\circ+\cos 72^\circ}$$

$$=\frac{\frac{1+\cos 72^\circ}{2}-\frac{1+\cos 144^\circ}{2}}{\cos 36^\circ+\cos 72^\circ}$$

$$=\frac{\cos 72^\circ+\cos 36^\circ}{2(\cos 36^\circ+\cos 72^\circ)}=\frac{1}{2}$$

(d) $\sin 10^\circ\sin 50^\circ\sin 70^\circ=\cos 20^\circ\cos 40^\circ\cos 80^\circ$

តាម $\sin 2x=2\sin x\cos x\Rightarrow\cos x=\frac{1}{2}\frac{\sin 2x}{\sin x}$

យើងបាន $\sin 10^\circ\sin 50^\circ\sin 70^\circ$

$$=\left(\frac{1}{2}\frac{\sin 40^\circ}{\sin 20^\circ}\right)\left(\frac{1}{2}\frac{\sin 80^\circ}{\sin 40^\circ}\right)\left(\frac{1}{2}\frac{\sin 160^\circ}{\sin 80^\circ}\right)$$

$$=\frac{1}{8}\frac{\sin 160^\circ}{\sin 20^\circ}=\frac{1}{8}\frac{\sin 20^\circ}{\sin 20^\circ}=\frac{1}{8}$$

**លំហាត់ ៤**

សម្រួលកន្សោម $\sqrt{\sin^4 x+4\cos^2 x}-\sqrt{\cos^4 x+4\sin^2 x}$ ។

**ចម្លើយ**

$$\sqrt{\sin^4 x+4\cos^2 x}-\sqrt{\cos^4 x+4\sin^2 x}$$
$$=\sqrt{\sin^4 x+4(1-\sin^2 x)}-\sqrt{\cos^4 x+4(1-\cos^2 x)}$$
$$=\sqrt{(2-\sin^2 x)^2}-\sqrt{(2-\cos^2 x)^2}$$
$$=2-\sin^2 x-2+\cos^2 x=\cos 2x$$

**លំហាត់ ៥**

បង្ហាញថា $1-\cot 23^\circ=\dfrac{2}{1-\cot 22^\circ}$ ។

**ចម្លើយ**

របៀបទី ១

យើងមាន $(1-\cot 23^\circ)(1-\cot 22^\circ)=\left(1-\dfrac{\cos 23^\circ}{\sin 23^\circ}\right)\left(1-\dfrac{\cos 22^\circ}{\sin 22^\circ}\right)$

$$=\frac{(\sin 23^\circ-\cos 23^\circ)(\sin 22^\circ-\cos 22^\circ)}{\sin 23^\circ\sin 22^\circ}$$
$$=\frac{2(\sin 23^\circ\cos 45^\circ-\sin 45^\circ\cos 23^\circ)(\sin 22^\circ\cos 45^\circ-\sin 45^\circ\cos 22^\circ)}{\sin 22^\circ\sin 23^\circ}$$
$$=\frac{2\sin(23^\circ-45^\circ)\sin(22^\circ-45^\circ)}{\sin 22^\circ\sin 23^\circ}$$
$$=\frac{2\sin 22^\circ\sin 23^\circ}{\sin 22^\circ\sin 23^\circ}=2$$

ហេតុនេះ $1-\cot 23^\circ=\dfrac{2}{1-\cot 22^\circ}$

របៀបទី ២

យើងមាន $\cot 45^\circ=\cot(22^\circ+23^\circ)=\dfrac{\cot 22^\circ\cot 23^\circ-1}{\cot 22^\circ+\cot 23^\circ}$

$$\Rightarrow \frac{\cot 22^\circ \cot 23^\circ - 1}{\cot 22^\circ + \cot 23^\circ} = 1$$

$$\Rightarrow \cot 22^\circ \cot 23^\circ - \cot 22^\circ - \cot 23^\circ - 1 = 2$$

$$\Rightarrow (\cot 23^\circ - 1)\cot 22^\circ - (\cot 23^\circ - 1) = 2$$

$$\Rightarrow (\cot 23^\circ - 1)(\cot 22^\circ - 1) = 2$$

ហេតុនេះ $1 - \cot 23^\circ = \dfrac{2}{1 - \cot 22^\circ}$

## លំហាត់ ៦

កំណត់ $x \in \left(0, \dfrac{\pi}{2}\right)$ បើគេដឹងថា $\dfrac{\sqrt{3}-1}{\sin x} + \dfrac{\sqrt{3}+1}{\cos x} = 4\sqrt{2}$ ។

## ចម្លើយ

យើងមាន $\dfrac{\sqrt{3}-1}{\sin x} + \dfrac{\sqrt{3}+1}{\cos x} = 4\sqrt{2} \Rightarrow \dfrac{\sqrt{3}-1}{2\sqrt{2}\sin x} + \dfrac{\sqrt{3}+1}{2\sqrt{2}\cos x} = 2$

$$\Rightarrow \frac{\sqrt{6}-\sqrt{2}}{4\sin x} + \frac{\sqrt{6}+\sqrt{2}}{4\cos x} = 2 \qquad (*)$$

តាម លំហាត់ ៤ (a) $\sin\dfrac{\pi}{12} = \dfrac{\sqrt{6}-\sqrt{2}}{4}$, $\cos\dfrac{\pi}{12} = \dfrac{\sqrt{6}+\sqrt{2}}{4}$

$$(*) \Rightarrow \frac{\sin\frac{\pi}{12}}{\sin x} + \frac{\cos\frac{\pi}{12}}{\cos x} = 2$$

$$\Rightarrow \sin\frac{\pi}{12}\cos x + \sin x\cos\frac{\pi}{12} = 2\sin x\cos x$$

$$\Rightarrow \sin\left(x + \frac{\pi}{12}\right) = \sin 2x$$

យើងបាន $\left[\begin{array}{l} x + \dfrac{\pi}{12} = 2x + 2k\pi \\ x + \dfrac{\pi}{12} = \pi - 2x + 2k\pi \end{array}\right. \Rightarrow \left[\begin{array}{l} x = \dfrac{\pi}{12} - 2k\pi \\ x = \dfrac{11\pi}{36} + \dfrac{2k\pi}{3} \end{array}\right.$

ដោយ $x \in \left(0, \frac{\pi}{2}\right)$

គេបាន $x = \frac{\pi}{12}$ , $x = \frac{11\pi}{36}$

## លំហាត់ ៧

យក $\Re$ ជាសំណុំនៃគូ $(x, y)$បំពេញលក្ខខណ្ឌ $x^2 + y^2 \le 100$ និង $\sin(x+y) \ge 0$ ។ គណនាផ្ទៃតំណាង $\Re$ ។

**ចម្លើយ**

របៀបទី ១



សំណុំចំណុច $(x, y)$បំពេញលក្ខខណ្ឌ $x^2 + y^2 \le 100$ ជាផ្ទៃកខាងក្នុងនៃរង្វង់ ដែល $(C)$មានកាំផ្ចិត $O(0,0)$ និង កាំ $R = 10$

បើ $\sin(x+y) = 0 \Rightarrow x + y = k\pi$ , $k \in Z$

សមីការអាប់ស៊ីសរវាងរង្វង់ $(C)$និង បន្ទាត់ $(l): x + y = k\pi$ រឺ $y = -x + k\pi$

កំណត់ដោយ $x^2 + (-x + k\pi)^2 = 100$

$$2x^2 - 2k\pi x + k^2\pi^2 - 100 = 0$$

មាន $\Delta' = k^2\pi^2 - 2k^2\pi^2 + 200 = -k^2\pi^2 + 200$

បើ $(C)$ប្រសព្វ $(l)$គេបាន $-k^2\pi^2 + 200 \ge 0 \Rightarrow k^2 \le \frac{200}{\pi^2} < \frac{200}{9}$

$$\Rightarrow -\frac{\sqrt{200}}{3} < k < \frac{\sqrt{200}}{3}$$

$$\Rightarrow -5 < k < 5$$

$$\Rightarrow -4 \le k \le 4$$

គេបាន រង្វង់ $(C)$ត្រូវបានចែកជា 10 តំបន់ផ្សេងគ្នាដូចរូប ( ដោយបន្ទាត់ចំនួន 9)

ហើយ រាល់តំបន់នីមួយៗផ្ទុករាល់គូ $(x, y)$បំពេញលក្ខខណ្ឌ $\sin(x+y) > 0$

រឺ $\sin(x-y)<0$ ។ សិក្សាលើតម្លៃ $k$ គេបាន ចំនួនគូ $(x,y)$ដែល $\sin(x+y)>0$ និង ចំនួនគូ $(x,y)$មានចំនួនស្មើគ្នា ។

យើងបាន ក្រឡាផ្ទៃតាង ℜ កំណត់ដោយ $S=\frac{10^2\pi}{2}=50\pi$

របៀបទី ២

យក $(C)$ជាថាសដែលកើតចេញពីចំណុច $(x,y)$បំពេញលក្ខខណ្ឌ $x^2+y^2\le 100$

យើងមាន $\sin(x+y)=0 \Leftrightarrow x+y=k\pi$ , $k\in Z$

ថាស $(C)$ត្រូវបានកាត់ដោយបន្ទាត់ $(D_k): x+y=k\pi$ (គ្រប់តម្លៃ $k$ គេបាន $(D_k): x+y=k\pi$ ជាបន្ទាត់ស្របគ្នា )

គេបាន តំបន់ដូចរូប ។ ក្នុងតំបន់នោះមានចំណុច $(x,y)$បំពេញលក្ខខណ្ឌ $\sin(x+y)\ge 0$រឺ $\sin(x+y)<0$

ចំពោះ $\forall(x,y)\in(C)$ គេបាន $\sin(-x-y)=-\sin(x+y)$

មានន័យថា ចំណុច $(x,y)$បំពេញលក្ខខណ្ឌ $\sin(x,y)>0$ និង ចំណុច $(x,y)$ បំពេញលក្ខខណ្ឌ $\sin(x,y)<0$ ឆ្លុះគ្នាធៀបនឹងគល់ $O$ ។

យើងបាន ចំនួនគូ $(x,y)$ផ្ទៀងផ្ទាត់ $\sin(x+y)\ge 0$ មានចំនួនស្មើគ្នានឹងចំនួនគូ $(x,y)$ផ្ទៀងផ្ទាត់ $\sin(x,y)<0$

យើងបាន ក្រឡាផ្ទៃតាង ℜ កំណត់ដោយ $S=\frac{10^2\pi}{2}=50\pi$

## លំហាត់ ៨

ចំពោះគ្រប់ត្រីកោណ $ABC$ បង្ហាញថា $\sin\frac{A}{2}\le\frac{a}{b+c}$ ។

**ចម្លើយ**

តាមទ្រឹស្តីបទស៊ីនុសយើងបាន $\frac{a}{b+c}=\frac{\sin A}{\sin B+\sin C}$

$$= \frac{2\sin\frac{A}{2}\cos\frac{A}{2}}{2\sin\left(\frac{B+C}{2}\right)\cos\left(\frac{B-C}{2}\right)}$$

$$= \frac{\sin\frac{A}{2}\cos\frac{A}{2}}{\cos\frac{A}{2}\cos\left(\frac{B-C}{2}\right)} = \frac{\sin\frac{A}{2}}{\cos\left(\frac{B-C}{2}\right)}$$

ដោយ $0 < \cos\left(\frac{B-C}{2}\right) \le 1$ ព្រោះ $0 \le |B-C| < \pi$

ហេតុនេះ $\sin\frac{A}{2} \le \frac{a}{b+c}$

**សម្គាល់** ស្រាយដូចគ្នា យើងបាន $\sin\frac{B}{2} \le \frac{b}{c+a}$, $\sin\frac{C}{2} \le \frac{c}{a+b}$

## លំហាត់ ៩

គេឲ្យ $I = \left[-\frac{\pi}{4}, \frac{\pi}{4}\right]$ និង $f$ ជាអនុវត្តន៍កំណត់លើ $[-1,1]$ ដោយ $f(\sin 2x) = \sin x + \cos x$ ។ កំណត់ $f$ រួច ទាញរក $f(\tan^2 x)$ ចំពោះ $\forall x \in I$ ។

## ចម្លើយ

យើងមាន $[f(\sin 2x)]^2 = (\sin x + \cos x)^2 = 1 + \sin 2x$

ដោយ $f : I \to [-1,1]$

$x \mapsto \sin 2x$ ជាអនុវត្តន៍មួយទល់មួយ

មានន័យថា $\forall t \in [-1,1],\ \exists! x \in I : t = \sin 2x$

យើងបាន $[f(t)]^2 = 1 + t$ ចំពោះ $t \in [-1,1] \Rightarrow f(t) = \sqrt{1+t}$

ព្រោះ $f(t) = f(\sin 2x) = \sin x + \cos x \ge 0$, $\forall x \in I$

ដូចនេះ $f(t) = \sqrt{1+t}$, $\forall t \in [-1,1]$

ចំពោះ $x \in I \Rightarrow -1 \le \tan x \le 1 \Rightarrow 0 \le \tan^2 x \le 1$

យើងបាន $f(\tan^2 x) = \sqrt{1+\tan^2 x} = \sec x$

## លំហាត់ ១០

យក $f_k(x) = \frac{1}{k}(\sin^k x + \cos^k x)$ ចំពោះ $k = 1, 2, \dots, n$ ។

បង្ហាញថា $f_4(x) - f_6(x) = \frac{1}{12}$ , $\forall x \in IR$ ។

## ចម្លើយ

ដើម្បីបង្ហាញថា $f_4(x) - f_6(x) = \frac{1}{12}$ យើងគ្រាន់តែបង្ហាញថា

$3(\sin^4 x + \cos^4 x) - 2(\sin^6 x + \cos^6 x) = 1$

យើងមាន $3(\sin^4 x + \cos^4 x) - 2(\sin^6 x + \cos^6 x)$

$$
\begin{aligned}
&= 3\left[(\sin^2 x + \cos^2 x)^2 - 2\sin^2 x\cos^2 x\right] \\
&\quad - 2(\sin^2 x + \cos^2 x)(\sin^4 x - \sin^2 x\cos^2 x + \cos^4 x) \\
&= 3 - 6\sin^2 x\cos^2 x - 2\left[(\sin^2 x + \cos^2 x)^2 - 3\sin^2 x\cos^2 x\right] \\
&= 3 - 6\sin^2 x\cos^2 x - 2 + 6\sin^2 x\cos^2 x \\
&= 1
\end{aligned}
$$

ហេតុនេះ $f_4(x) - f_6(x) = \frac{1}{12}$ , $\forall x \in IR$

## លំហាត់ ១១

(AIME,2004)

រង្វង់មួយមានកាំ 1 ឯកតា ត្រូវបានគេយកទៅដាក់ក្នុងចតុកោណកែង $ABCD$ មួយដែលមានទំហំ $15 \times 36$ ( គ្មានផ្នែកណានៃរង្វង់ស្ថិតនៅក្រៅចតុកោណ ) ។ កំណត់ប្រូបាប៊ីលីតេដែលរង្វង់មិនកាត់អង្កត់ទ្រូង $AC$ ។

## ចម្លើយ




ដើម្បីឲ្យរង្វង់នៅក្នុងចតុកោណកែង $ABCD$ កាលណាផ្ចិត $O$ នៃរង្វង់នោះស្ថិតនៅក្នុងចតុកោណទំហំ $(15-2)\times(36-2)=13\times 34$

ព្រឹត្តិការណ៍រង្វង់មិនប៉ះអង្កត់ទ្រូង $AC$ ដូចគ្នានឹងព្រឹត្តិការណ៍ចម្ងាយពីផ្ចិត $O$ ទៅជ្រុង $AC$ ធំជាង 1 រឺ ដូចគ្នានឹងព្រឹត្តិការណ៍ចម្ងាយពីផ្ចិត $O$ ទៅជ្រុងនៃត្រីកោណ $ABC$ និង ត្រីកោណ $CDA$ ធំជាង 1។

យើងគូសអង្កត់បីស្របគ្នានឹងជ្រុងនៃត្រីកោណ $ABC$ និង $CDA$

( គម្លាតពីអង្កត់ទាំងនោះនឹងជ្រុងនៃត្រីកោណស្មើនឹង 1 ដូចរូប )

ដោយជ្រុងត្រូវគ្នានៃត្រីកោណ $EFG$ និង ត្រីកោណ $ABC$ ស្របគ្នា

យើងបាន ត្រីកោណ $EFG$ និង ត្រីកោណ $ABC$ ជាត្រីកោណដូចគ្នា

$$\Rightarrow \frac{[EFG]}{[ABC]}=\left(\frac{EF}{AB}\right)^2 \Rightarrow [EFG]=[ABC]\left(\frac{EF}{AB}\right)^2=15\times 36\left(\frac{EF}{AB}\right)^2$$

បើ $A$ ជាព្រឹត្តិការណ៍ដែលរង្វង់មិនកាត់អង្កត់ទ្រូង $AC$

យើងបាន $P(A)=\dfrac{2[EFG]}{13\times 34}=\dfrac{15\times 36}{13\times 34}\left(\dfrac{EF}{AB}\right)^2=\dfrac{270}{221}\left(\dfrac{EF}{AB}\right)^2$

ដោយចម្ងាយពី $E$ ទៅជ្រុង $AB$ និង $AC$ មានប្រវែងស្មើគ្នា គឺ 1ឯកតា

$\Rightarrow E$ ស្ថិតលើកន្លះបន្ទាត់ពុះ $\angle BAC$

ដូចគ្នាដែរ $F$ , $G$ ស្ថិតនៅលើកន្លះបន្ទាត់ពុះ $\angle ABC$ , $\angle BCA$

យើងបាន $AE$ , $BF$ និង $CG$ ប្រសព្វគ្នាត្រង់ចំណុច $I$ ដែលជាផ្ចិតរង្វង់ចារឹកក្នុងនៃត្រីកោណ $ABC$

របៀបទី ១

យក $E_1$, $F_1$ ជាចំណោលកែងនៃ $E$ , $F$ លើជ្រុង $AB$

$\Rightarrow EE_1F_1F$ ជាចតុកោណកែង

យើងបាន $EF = E_1F_1$ និង $BF_1 = FF_1 = EE_1 = 1$

បើ $\angle EAB = \theta \Rightarrow \angle CAB = 2\theta$

យើងបាន $\sin 2\theta = \dfrac{BC}{AC} = \dfrac{15}{39} = \dfrac{5}{13}$, $\cos 2\theta = \dfrac{AB}{AC} = \dfrac{36}{39} = \dfrac{12}{13}$

$$\Rightarrow \tan\theta = \frac{1-\cos 2\theta}{\sin 2\theta} = \frac{1-\frac{12}{13}}{1-\frac{5}{13}} = \frac{1}{5} \Rightarrow AE_1 = \frac{EE_1}{\tan\theta} = 5$$

$\Rightarrow EF = E_1F_1 = AB - BF_1 - AE_1 = 36 - 1 - 5 = 30$

ហេតុនេះ $\dfrac{m}{n} = \left(\dfrac{30}{36}\right)^2\left(\dfrac{270}{221}\right) = \dfrac{375}{442} \Rightarrow m+n = 817$

របៀបទី ២

តាង $A(0,0)$, $B(36,0)$និង $C(36,15)$

ដោយ $E$ ស្ថិតនៅលើកន្លះបន្ទាត់ពុះនៃ $\angle CAB$

$\Rightarrow \overrightarrow{AE}$ មានមេគុណប្រាប់ទិសដូចគ្នានឹង $\left|\overrightarrow{AB}\right|\overrightarrow{AC} + \left|\overrightarrow{AC}\right|\overrightarrow{AB}$

ដោយ $\left|\overrightarrow{AB}\right|\overrightarrow{AC} + \left|\overrightarrow{AC}\right|\overrightarrow{AB} = 36(36,15) + 39(36,0) = 36\cdot 15(5,1)$

$\Rightarrow \dfrac{1}{5}$ ជាមេគុណប្រាប់ទិសនៃ $AE \Rightarrow \tan\theta = \dfrac{1}{5}$ ( យក $\theta = \angle EAB$ )

យើងបាន $AE_1 = \dfrac{EE_1}{\tan\theta} = 5$

$\Rightarrow EF = E_1F_1 = AB - BF_1 - AE_1 = 36 - 1 - 5 = 30$

ហេតុនេះ $\dfrac{m}{n} = \left(\dfrac{30}{36}\right)^2\left(\dfrac{270}{221}\right) = \dfrac{375}{442} \Rightarrow m+n = 817$

របៀបទី ៣

ដោយ គ្រប់ជ្រុងត្រូវគ្នានៃត្រីកោណ $ABC$ និង $EFG$ សុទ្ធតែស្របគ្នា

$\Rightarrow I$ ក៏ជាផ្ចិតរង្វង់ចារឹកក្នុងនៃត្រីកោណ $EFG$

បើ $r$ ជាប្រវែងកាំនៃរង្វង់ចារឹកក្នុងនៃត្រីកោណ $ABC$

$\Rightarrow r' = r - BF_1 = r - 1$ ( $r'$ ជាកាំរង្វង់ចារឹកក្នុងត្រីកោណ $ABC$ )

យើងបាន $\dfrac{EFG}{ABC} = \left(\dfrac{r-1}{r}\right)^2 \Rightarrow \dfrac{m}{n} = \left(\dfrac{r-1}{r}\right)^2 \left(\dfrac{270}{221}\right)$

តែ $r(AB + BC + CA) = 2([AIB] + [BIC] + [CIA])$

$$= 2[ABC] = AB \cdot BC$$

$$\Rightarrow r = \frac{AB \cdot BC}{AB + BC + CA} = \frac{36 \cdot 15}{36 + 15 + 39} = 6$$

គេបាន $\dfrac{m}{n} = \left(\dfrac{6-1}{6}\right)^2 \left(\dfrac{270}{221}\right) = \dfrac{375}{442}$

ហេតុនេះ $\qquad m + n = 812$

## លំហាត់ ១២

(AMC 12,1999)

គេឲ្យត្រីកោណ $ABC$ មួយបំពេញលក្ខខណ្ឌ $3\sin A + 4\cos B = 6$ និង $4\sin B + 3\cos A = 1$ ។ គណនាមុំ $C$ ។

**ចម្លើយ**

យើងមាន $\qquad 3\sin A + 4\cos B = 6 \quad (1)$

$\qquad\qquad 4\sin B + 3\cos A = 1 \quad (2)$

តាម (1) $\Rightarrow 9\sin^2 A + 24\sin A\cos B + 16\cos^2 B = 36 \qquad (3)$

តាម (1) $\Rightarrow 16\sin^2 B + 24\sin B\cos A + 9\cos^2 A = 1 \qquad (4)$

បូក (3),(4) យើងបាន $25 + 24\sin(A + B) = 37 \Rightarrow \sin(A + B) = \dfrac{1}{2}$

$$\Rightarrow \sin C = \frac{1}{2} \Rightarrow C = \frac{\pi}{6} \text{ រឺ } \frac{5\pi}{6}$$

បើ $C = \dfrac{5\pi}{6} \Rightarrow A < \dfrac{\pi}{6}$ គេបាន $3\sin A + 4\cos B < \dfrac{3}{2} + 4 < 6$ មិនពិត

ហេតុនេះ $\qquad C = \dfrac{\pi}{6}$

## លំហាត់ ១៣

បង្ហាញថា $\tan 3a - \tan 2a - \tan a = \tan 3a \tan 2a \tan a$

ចំពោះ $\forall a \neq \frac{k\pi}{2}$, $k \in Z$ ។

**ចម្លើយ**

យើងមាន $\tan 3a = \tan(2a + a) = \frac{\tan a + \tan 2a}{1 - \tan a \tan 2a}$

$\Rightarrow \tan 3a - \tan a \tan 2a \tan 3a = \tan a + \tan 2a$

ហេតុនេះ $\tan 3a - \tan 2a - \tan a = \tan 3a \tan 2a \tan a$

**សម្គាល់** បើ $a_1$, $a_2$, $a_3 \neq \frac{k\pi}{2}$ ( $k \in Z$ ) បំពេញលក្ខខណ្ឌ $a_1 + a_2 + a_3 = 0$

គេបាន $\tan a_1 + \tan a_2 + \tan a_3 = \tan a_1 \tan a_2 \tan a_3$ ។

## លំហាត់ ១៤

គេឲ្យ $a$, $b$, $c$, $d \in [0, \pi]$ បំពេញលក្ខខណ្ឌ

$\sin a + 7\sin b = 4(\sin c + 2\sin d)$ និង

$\cos a + 7\cos b = 4(\cos c + 2\cos d)$ ។

បង្ហាញថា $2\cos(a - d) = 7\cos(b - c)$ ។

**ចម្លើយ**

យើងមាន $\sin a + 7\sin b = 4(\sin c + 2\sin d) \quad (1)$

$\cos a + 7\cos b = 4(\cos c + 2\cos d) \quad (2)$

តាម (1): $\sin a + 7\sin b = 4(\sin c + 2\sin d)$

$\Rightarrow \sin a - 8\sin d = 4\sin c - 7\sin b$

$\Rightarrow \sin^2 a - 16\sin a \sin d + 64\sin^2 d$

$= 16\sin^2 c - 56\sin b \sin c + 49\sin^2 b \quad (3)$

តាម (1): $\cos a + 7\cos b = 4(\cos c + 2\cos d)$

$\Rightarrow \cos a - 8\cos d = 4\cos c - 7\cos b$

$\Rightarrow \cos^2 a - 16\cos a \cos d + 64\cos^2 d$

$$=16\cos^2 c-56\cos b\cos c+49\cos^2 b \qquad (4)$$

បូក (3),(4) យើងបាន $1-16\cos(a-d)+64=16-56\cos(b-c)+49$

$$\Rightarrow 2\cos(a-d)=7\cos(b-c)$$

ហេតុនេះ $2\cos(a-d)=7\cos(b-c)$

## លំហាត់ ១៥

សរសេរ $\sin(x-y)+\sin(y-z)+\sin(z-x)$ ជាផលគុណកត្តា ។

**ចម្លើយ**

$$\sin(x-y)+\sin(y-z)+\sin(z-x)$$

$$=2\sin\left(\frac{x-z}{2}\right)\cos\left(\frac{x+z-2y}{2}\right)+2\sin\left(\frac{z-x}{2}\right)\cos\left(\frac{z-x}{2}\right)$$

$$=2\sin\left(\frac{x-z}{2}\right)\left[\cos\left(\frac{x+z-2y}{2}\right)-\cos\left(\frac{z-x}{2}\right)\right]$$

$$=-4\sin\left(\frac{x-z}{2}\right)\sin\left(\frac{z-y}{2}\right)\sin\left(\frac{x-y}{2}\right)$$

$$=-4\sin\left(\frac{x-y}{2}\right)\sin\left(\frac{y-z}{2}\right)\sin\left(\frac{z-x}{2}\right)$$

**សម្គាល់**

បើ $a+b+c=0$ គេបាន $\sin a+\sin b+\sin c=-4\sin\frac{a}{2}\sin\frac{b}{2}\sin\frac{c}{2}$ ។

## លំហាត់ ១៦

បង្ហាញថា $(4\cos^2 9^\circ-3)(4\cos^2 27^\circ-3)=\tan 9^\circ$ ។

**ចម្លើយ**

$$\cos 3x=3\cos x-4\cos^3 x\Rightarrow 4\cos^2 x-3=\frac{\cos 3x}{\cos x},\forall x\neq\frac{k\pi}{2},k\in Z$$

យើងបាន $(4\cos^2 9^\circ-3)(4\cos^2 27^\circ-3)=\left(\frac{\cos 27^\circ}{\cos 9^\circ}\right)\left(\frac{\cos 81^\circ}{\cos 27^\circ}\right)$

$$= \frac{\cos 81^\circ}{\cos 9^\circ} = \frac{\sin 9^\circ}{\cos 9^\circ}$$
$$= \tan 9^\circ$$

**លំហាត់ ១៧**

បង្ហាញថា $\left(1+\frac{a}{\sin x}\right)\left(1+\frac{b}{\cos x}\right) \geq \left(1+\sqrt{2ab}\right)^2$ ចំពោះ $\forall a,b \geq 0$

និង $0 < x < \frac{\pi}{2}$ ។

**ចម្លើយ**

យើងមាន $\left(1+\frac{a}{\sin x}\right)\left(1+\frac{b}{\cos x}\right) \geq \left(1+\sqrt{2ab}\right)^2$

$$\Leftrightarrow 1+\frac{a}{\sin x}+\frac{b}{\cos x}+\frac{ab}{\sin x\cos x} \geq 1+2\sqrt{2ab}+2ab$$
$$\Leftrightarrow \frac{a}{\sin x}+\frac{b}{\cos x}+\frac{ab}{\sin x\cos x} \geq 2\sqrt{2ab}+2ab$$

តាម AM-GM យើងបាន $\frac{a}{\sin x}+\frac{b}{\cos x} \geq \frac{2\sqrt{ab}}{\sqrt{\sin x\cos x}}$ (*)

ដោយ $\sin 2x = 2\sin x\cos x \Rightarrow 2\sin x\cos x \leq 1$

$$\Rightarrow \sin x\cos x \leq \frac{1}{2}$$

(*) $\Rightarrow \frac{a}{\sin x}+\frac{b}{\cos x} \geq 2\sqrt{2ab}$ (1)

និង $\frac{ab}{\sin x\cos x} \geq 2ab$ (2)

តាម (1),(2) យើងបាន $\frac{a}{\sin x}+\frac{b}{\cos x}+\frac{ab}{\sin x\cos x} \geq 2\sqrt{2ab}+2ab$

ហេតុនេះ $\left(1+\frac{a}{\sin x}\right)\left(1+\frac{b}{\cos x}\right) \geq \left(1+\sqrt{2ab}\right)^2$

**លំហាត់ ១៨**

គេឲ្យត្រីកោណ $ABC$ បំពេញលក្ខខណ្ឌ $\sin A+\sin B+\sin C \leq 1$ ។

បង្ហាញថា $\min\{A+B, B+C, C+A\} < 30°$ ។

**ចម្លើយ**

WLOG ឧបមាថា $A \geq B \geq C$ គេបាន $A+B \geq C+A \geq B+C$

ហេតុនេះ ដើម្បីបង្ហាញថា $\min\{A+B, B+C, C+A\} < 30°$

យើងគ្រាន់តែបង្ហាញថា $B+C < 30°$

យើងមាន $b+c > a \Rightarrow \sin B + \sin C > \sin A$ (ទ្រឹស្តីបទស៊ីនុស )

$$\Rightarrow \sin A + \sin B + \sin C > 2\sin A$$

ដោយ $\sin A + \sin B + \sin C \leq 1$

យើងបាន $1 > 2\sin A \Rightarrow \sin A < \dfrac{1}{2} \Rightarrow 0 < A < 30°$ រឺ $150° < A < 180°$

បើ $A < 30° \Rightarrow A+B+C < 30°+30°+30° = 90°$ មិនពិត

ព្រោះ $A$, $B$, $C$ ជារង្វាស់មុំនៃត្រីកោណមួយ

$\Rightarrow A > 150° \Rightarrow B+C = 180° - A < 30°$

សរុបមក $\min\{A+B, B+C, C+A\} < 30°$

**លំហាត់ ១៩**

ចំពោះត្រីកោណ $ABC$ បង្ហាញថា

(a) $\tan\dfrac{A}{2}\tan\dfrac{B}{2} + \tan\dfrac{B}{2}\tan\dfrac{C}{2} + \tan\dfrac{C}{2}\tan\dfrac{A}{2} = 1$

(b) $\tan\dfrac{A}{2}\tan\dfrac{B}{2}\tan\dfrac{C}{2} \leq \dfrac{\sqrt{3}}{9}$ ។

**ចម្លើយ**

(a)

យើងមាន $\dfrac{A+B+C}{2} = \dfrac{\pi}{2} \Rightarrow \dfrac{A}{2} + \dfrac{B}{2} = \dfrac{\pi}{2} - \dfrac{C}{2}$

$$\Rightarrow \tan\left(\frac{A}{2} + \frac{B}{2}\right) = \tan\left(\frac{\pi}{2} - \frac{C}{2}\right)$$

$$\Rightarrow \frac{\tan\frac{A}{2}+\tan\frac{B}{2}}{1-\tan\frac{A}{2}\tan\frac{B}{2}}=\frac{1}{\tan\frac{C}{2}}$$

$$\Rightarrow \tan\frac{A}{2}\tan\frac{C}{2}+\tan\frac{B}{2}\tan\frac{C}{2}=1-\tan\frac{A}{2}\tan\frac{B}{2}$$

ដូចនេះ $\tan\frac{A}{2}\tan\frac{B}{2}+\tan\frac{B}{2}\tan\frac{C}{2}+\tan\frac{C}{2}\tan\frac{A}{2}=1$

